ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរអប់រំ យុវជន និងកីឡាខេត្តកែប
ក្រុមលទ្ធកម្ម
លេខ : ០២០ អយក.គ.ល

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃ ការងារជួសជុលអគារសិក្សា នៅសាលាបឋមសិក្សាហ៊ុន សែន ព្រែកតានេន ១ខ្នង ៥បន្ទប់ និងនៅសាលាបឋមសិក្សាស្បូវ ២ខ្នង ៦បន្ទប់ ជូនមន្ទីរអប់រំ យុវជន និងកីឡាខេត្តកែប

អាជ្ញាធរជាតិលទ្ធកម្ម
នាយកដ្ឋានលទ្ធកម្មសាធារណៈ

មន្ទីរអប់រំ យុវជន និងកីឡាខេត្តកែប សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា មន្ទីរអប់រំ យុវជន និងកីឡាខេត្តកែប នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការធ្វើការងារជួសជុលអគារសិក្សានៅសាលាបឋមសិក្សាហ៊ុន សែន ព្រែកតានេន ១ខ្នង ៥បន្ទប់ និងនៅសាលាបឋមសិក្សាស្បូវ ២ខ្នង ៦បន្ទប់ (ជួសជុលតួអគារ ប្តូរទ្វារ បង្អួច ចាក់ឡប់ឡៃជុំវិញអគារ ខាត់ បៀកលាបថ្នាំជញ្ជាំងក្រៅ ក្នុង និងរុះរើដំបូលទាំងអស់) ជូនមន្ទីរអប់រំ យុវជន និងកីឡាខេត្តកែប ។

មន្ទីរអប់រំ យុវជន និងកីឡាខេត្តកែប បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តកែប ដែលមានអាសយដ្ឋានភូមិថ្មី សង្កាត់ព្រៃធំ ខេត្តកែប ចាប់ពីថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០១៨ តទៅ វៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ........................................................) ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនក្រុមលទ្ធកម្មមន្ទីរអប់រំ យុវជន និងកីឡាខេត្តកែប យ៉ាងយូរបំផុតត្រឹមថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ២០១៨ វេលាម៉ោង ០៩:០០ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តកែប តាមអាសយដ្ឋានខាងលើ វេលាម៉ោង ០៩:០០ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ២០១៨ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយក្រុមលទ្ធកម្មមន្ទីរអប់រំ យុវជន និងកីឡាខេត្តកែប ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ។

ថ្ងៃ [illegible] ខែកត្តិក ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២
ធ្វើនៅកែប ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០១៨
**ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តកែប**
**និងជាប្រធានក្រុមលទ្ធកម្ម**

ខុន ច័ន្ទសុជាតា

ចម្លងជូន ៖
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ

3